**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឆ្នាំទី២១ លេខ៨៨ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

**ផ្សាយចេញពី**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**សារបាន**

**ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស**

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ចឹង ក័ងជា** (TSENG KUAN-CHIEH) ជនជាតិចិន សញ្ជាតិចិន (តៃវ៉ាន់) ១០៨៦៧

២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៨៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី ហ្គួលាន** (LI GUOLIAN) ជនជាតិចិន សញ្ជាតិចិន ១០៨៦៨


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៨-១២-២០២១ -អនុក្រឹត្យលេខ ២៧១ អនក្រ.បក ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិអប្សរា ១០៨៦៩

៣១-១២-២០២១ -អនុក្រឹត្យលេខ ៦០៤ អនក្រ.តត ស្តីពី ការតម្លើងឋានៈ និងតែងតាំងមន្ត្រីរាជការ ១០៨៨៧


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១០-១១-២០២១ -ប្រកាសលេខ ៧៥៦ សហវ.ប្រក ស្តីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ១០៨៨៨

១១-១១-២០២១ -ប្រកាសលេខ ៧៦៦ សហវ.ប្រក ស្តីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១០៨៩១

២២-១១-២០២១ -ប្រកាសលេខ ៧៨២ សហវ.ប្រក ស្តីពី ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ ១០៨៩៤


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


២៤-១១-២០២១ -ប្រកាសលេខ ៤១៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី បង្កើតរោងចក្រ ផលិតស្បែកជើង ១០៨៩៦

២៤-១១-២០២១ -ប្រកាសលេខ ៤១៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូវ ស្តារ ស៊ូ ខូ អិលធីឌី បង្កើតរោងចក្រ ផលិតស្បែកជើង ១០៨៩៩

២៦-១១-២០២១ -ប្រកាសលេខ ៤១៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេសឌី ជីនដា ហ្គាមិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៩០២

២៦-១១-២០២១ -ប្រកាសលេខ ៤២០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡាស៊ីងវីននើរ ហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៩០៥

២៦-១១-២០២១ -ប្រកាសលេខ ៤២១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឆេមថេក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៩០៨

## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


៨-២-២០២១ -ប្រកាសលេខ ០១៨៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៨៤ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩១១

៨-២-២០២១ -ប្រកាសលេខ ០១៨៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៨៥ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩១៥

១១-២-២០២១ -ប្រកាសលេខ ០១៩១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៩១ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩១៩

១១-២-២០២១ -ប្រកាសលេខ ០១៩២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៩២ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩២៣

១១-២-២០២១ -ប្រកាសលេខ ០១៩៥ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៩៥ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩២៧

១១-២-២០២១ -ប្រកាសលេខ ០១៩៧ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៩៧ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៣១

១១-២-២០២១ -ប្រកាសលេខ ០១៩៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៩៨ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៣៥

១១-២-២០២១ -ប្រកាសលេខ ០១៩៩ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៩៩ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៣៩

១១-២-២០២១ -ប្រកាសលេខ ០២០១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០២០១ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៤៣

១១-២-២០២១ -ប្រកាសលេខ ០២០៣ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០២០៣ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៤៧

១៥-២-២០២១ -ប្រកាសលេខ ០២១៦ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០២១៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៩៥១


## ៤~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់


២២-១១-២០២១ -ប្រកាសលេខ ១០៩ ដនស/ប្រក/នី.ក ស្ដីពី បែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោង
ប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់ ១០៩៥៥


## ៥~ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


៥-១១-២០២១ -ប្រកាសលេខ ១៥៦ កយ.ប្រក/២១ ស្ដីពី ការផ្លាស់មន្ត្រីរាជការ ១០៩៩១

៧-១២-២០២១ -ប្រកាសលេខ ១៧៣ កយ.ប្រក/២១ ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ១០៩៩២

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៨៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចឹង គាំងជា** (TSENG KUAN-CHIEH) ជនជាតិ ចិន សញ្ជាតិ ចិន(តៃវ៉ាន់) កើតនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លី ហ្គួលាន** (LI GUOLIAN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧១ នៅខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានបម្រុងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៣៧១ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិអប្សរា

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ

- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិអប្សរា ។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពនៃអាជ្ញាធរជាតិអប្សរា ។

**ជំពូកទី២**

**បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ**

**ផ្នែកទី១**

**បេសកកម្ម មុខងារ និងភារកិច្ច**

**មាត្រា៣.-**

អាជ្ញាធរជាតិអប្សរា បំពេញមុខងារជាសេនាធិការឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើបេសកកម្ម ដឹកនាំ គ្រប់គ្រង ការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៤.-**

អាជ្ញាធរជាតិអប្សរា មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- ការពារ ថែរក្សា អភិរក្ស គ្រប់គ្រង និងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានអង្គរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀតដែលត្រូវបានប្រគល់ជូន
- សិក្សារៀបចំ និងគ្រប់គ្រងធនធានធម្មជាតិដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរក្សាតុល្យភាពបរិស្ថាន ទឹក ព្រៃឈើ ដីធ្លី និងគុណភាពដីក្នុងតំបន់ទាំង ៥ ដែលបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- សិក្សាលើកតម្លៃ និង/ឬដាក់ឱ្យដំណើរការឡើងវិញនូវគោលការណ៍ប្រតិបត្តិអង្គរ និងហេដ្ឋារចនាសម្ព័ន្ធអង្គរ ដូចជាប្រព័ន្ធទឹកបុរាណ ផ្លូវបុរាណ និងបេតិកភណ្ឌបុរាណ
- សិក្សារៀបចំអនុវត្តឱ្យបានសម្រេចនូវរាល់ផែនការសកម្មភាព រួមមានកម្មវិធីនៃការរៀបចំមូលដ្ឋាននានាសម្រាប់ការអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ទាំង៥ ដែលបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- គ្រប់គ្រង និងចាត់ចែងតំបន់បុរីសណ្ឋាគារ ឬហៅម្យ៉ាងទៀតថា បុរីវប្បធម៌ និងទេសចរណ៍ ឱ្យស្របតាមស្តង់ដារតំបន់ទ្រនាប់នៃឧទ្យានអង្គរ ដែលជាបេតិកភណ្ឌពិភពលោក
- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគសម្រាប់អភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់សៀមរាប-អង្គរ ជាពិសេសរៀបចំនិងអនុវត្តឱ្យបានសម្រេចនូវគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីជាគុណប្រយោជន៍ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ

- សហការជាមួយអាជ្ញាធរខេត្ត មន្ទីរ/ក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រប់វិទ្យាស្ថាន មូលនិធិ អង្គការជាតិ និងអន្តរជាតិនានា ដែលមានគោលបំណងស្របនឹងទិសដៅរបស់អាជ្ញាធរជាតិអប្សរា
- សម្របសម្រួល និងសហការជាមួយអង្គភាពនានាដែលបំពេញភារកិច្ចក្នុងតំបន់អង្គរចំពោះកិច្ចការពារបេតិកភណ្ឌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងការផ្តល់សេវាកម្មទេសចរណ៍ក្នុងឧទ្យានអង្គរ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ។

## ផ្នែកទី២
## រចនាសម្ព័ន្ធ

**មាត្រា៥.-**

អង្គភាពប្រតិបត្តិរបស់អាជ្ញាធរជាតិអប្សរា មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា

២. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌

៣. នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ

៤. នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍

៥. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

៦. នាយកដ្ឋានសណ្តាប់ធ្នាប់

៧. នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ

៨. នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

អាជ្ញាធរជាតិអប្សរា មានអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ អង្គភាពគ្រប់គ្រងភូមិធម្មជាតិរុនតាឯក និងមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា សម្រាប់សម្របសម្រួលការងារជាមួយស្ថាប័នជាតិ និងអន្តរជាតិ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

អាជ្ញាធរជាតិអប្សរា មានអង្គភាពសវនកម្មផ្ទៃក្នុងមួយ ជាសេនាធិការលើកិច្ចការសវនកម្ម ។

អាជ្ញាធរជាតិអប្សរា មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ជាសេនាធិការលើការងារលទ្ធកម្មសាធារណៈ និងគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ជាសេនាធិការលើការងារបញ្ជីសារពើភណ្ឌ ដែលត្រូវបង្កើតអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

អង្គការលេខរបស់អាជ្ញាធរជាតិអប្សរា ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៦.-**

អាជ្ញាធរជាតិអប្សរា ដឹកនាំដោយអគ្គនាយក ១ (មួយ)រូប និងមានអគ្គនាយករងជាជំនួយការ ចំនួនច្រើនបំផុត ៥(ប្រាំ)រូប។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ១ (មួយ)រូប និងមានអនុប្រធានជាជំនួយការ ចំនួនច្រើនបំផុត ៥ (ប្រាំ)រូប ។

នាយកដ្ឋាននីមួយៗ មានការិយាល័យមួយចំនួនជាសេនាធិការ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនៃនាយកដ្ឋាន អង្គភាព និងមជ្ឈមណ្ឌលចំណុះអាជ្ញាធរជាតិអប្សរា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ប្រធាននាយកដ្ឋាន ត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យចុះក្រោមត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតាមសំណើរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា តាមការឯកភាពរបស់ក្រុមប្រឹក្សាភិបាល។

## ជំពូកទី៣
## នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា

**មាត្រា៧.-**

នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា មានមុខងារនិងភារកិច្ចដូចតទៅ÷

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការអភិរក្សប្រាសាទនិងកិច្ចការបុរាណវិទ្យា
- រៀបចំឯកសារស្តីពីស្ថានភាពប្រាសាទ ផែនទីហានិភ័យប្រាសាទ និងរបាយការណ៍ ស្តីពីស្ថានភាពនៃការអភិរក្ស
- សិក្សា និងសម្រេចប្លង់បច្ចេកទេសរបស់ប្រាសាទនានា
- រៀបចំចុះបញ្ជី និងគ្រប់គ្រងសម្បត្តិបុរាណ ប្រាសាទ ព្រមទាំងរចនាសម្ព័ន្ធបុរាណក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំកម្មវិធី និងអនុវត្តការងារអភិរក្សប្រាសាទ និងរចនាសម្ព័ន្ធបុរាណនានា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ចូលរួមរៀបចំទីលានប្រាសាទ ជាពិសេសរៀបចំប្លង់ស្ថាបត្យកម្មនៃការអភិរក្ស ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា នៅតាមទីលានជុំវិញប្រាសាទឱ្យស្របតាមបទដ្ឋាននៃការអភិរក្សនិងអភិវឌ្ឍន៍ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- យកចិត្តទុកដាក់ជាប្រចាំក្នុងកិច្ចការពារ ថែទាំ ទល់ទ្រ ប្រាសាទនានា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសផ្នែកបុរាណវិទ្យាស្តីពីគម្រោងអភិរក្ស និងគម្រោងអភិវឌ្ឍន៍នានា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ចាត់វិធានការការពារតំបន់បុរាណវិទ្យា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ចូលរួមរៀបចំ និងអនុវត្តនូវរាល់កម្មវិធីស្រាវជ្រាវលើវិស័យបុរាណវិទ្យា និងការងារអភិរក្សប្រាសាទ និងវត្ថុបុរាណ

- ធ្វើការតាមដាន ត្រួតពិនិត្យ និងសម្របសម្រួលការដ្ឋានជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងការងារអភិរក្ស និងបុរាណវិទ្យា
- ចូលរួមប្រមូល ចងក្រងឯកសារ និងផ្សព្វផ្សាយនូវលទ្ធផលអភិរក្ស និងស្រាវជ្រាវ
- ចូលរួមសិក្សាស្រាវជ្រាវ និងអភិរក្សវត្ថុបុរាណធ្វើអំពីដីដុត លោហៈធាតុ ឈើ ភ្លុក ឆ្អឹង ថ្ម កែវ និងសារធាតុសរីរាង្គដទៃទៀត ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ចូលរួមរៀបចំកម្មវិធីស្រាវជ្រាវ និងបណ្តុះបណ្តាល ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៤
## នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌

**មាត្រា៨.-**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ មានមុខងារនិងភារកិច្ចដូចតទៅ÷

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ក្នុងឧទ្យានអង្គរ និងតំបន់ផ្សេងទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ស្តីពីការអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌អង្គរប្រកបដោយចីរភាព
- រៀបចំកម្មវិធីអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដែលស្ថិតក្នុងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ និងលើកកម្ពស់ឧស្សាហកម្មច្នៃប្រឌិត ក្នុងវិស័យទេសចរណ៍ដោយសហការជាមួយដៃគូរពាក់ព័ន្ធជាតិ និងអន្តរជាតិ
- ប្រមូល កសាងប្រព័ន្ធទិន្នន័យ វិភាគស្ថិតិភ្ញៀវទេសចរ ដែលស្ថិតក្នុងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ ដោយសហការជាមួយដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនិងសិក្សាអំពីភ្ញៀវទេសចរ ដើម្បីអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព និងសិក្សាបង្កើតផលិតផលទេសចរណ៍ថ្មី
- ចូលរួមសិក្សា និងរៀបចំទីលានមុខប្រាសាទ "ប៉ារីស " ចំណត មណ្ឌលបដិសណ្ឋារកិច្ច មណ្ឌលផ្តល់ព័ត៌មាន សម្ភារបរិក្ខាសម្រាប់សម្រួលដល់ការទស្សនា និងធានាសុវត្ថិភាពភ្ញៀវទេសចរ
- សិក្សារៀបចំប្លង់ ទស្សនាចររបស់ភ្ញៀវទេសចរនៅតាមប្រាសាទ ដើម្បីបង្កើនការយល់ដឹងអំពីគុណតម្លៃរបស់ប្រាសាទ ធានាសុវត្ថិភាព និងកាត់បន្ថយផលប៉ះពាល់ដោយផ្ទាល់របស់ភ្ញៀវទេសចរទៅលើប្រាសាទ
- រៀបចំ និងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅតាមប្រាសាទនានា ពិសេសដើម្បីធានាចំណូលខ្ពស់ពីព្រឹត្តិការណ៍ វប្បធម៌ សិល្បៈ មហោស្រប និងពិធីនានា និងរក្សាតុល្យភាពពីផលប៉ះពាល់ផ្សេងៗដែលបានប្រារព្ធធ្វើក្នុងតំបន់សៀមរាប-អង្គរ

- យកចិត្តទុកដាក់ការពាររូបភាពនៃប្រាសាទអង្គរ ដែលជានិមិត្តរូបជាតិ និងជាបេតិកភណ្ឌពិភពលោក ដោយចូលរួមតាមដានឱ្យបានហ្មត់ចត់លើសកម្មភាព ថតរូប ថតវីដេអូ និងភាពយន្ត
- សិក្សា និងរៀបចំបទប្បញ្ញត្តិ និងវិធានការពាក់ព័ន្ធក្នុងការផ្តល់សេវាកម្ម និងសកម្មភាពនានាក្នុងឧទ្យានអង្គរ និងតាមដានការអនុវត្តបទប្បញ្ញត្តិ និងវិធានការទាំងនោះ
- សហការរៀបចំវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស
- ចូលរួមផ្តល់យោបល់ និងរៀបចំកិច្ចសន្យាសម្រាប់គម្រោងវិនិយោគ និងអាជីវកម្មទេសចរណ៍ និងរៀបចំលិខិតអនុញ្ញាតចេញ ចូលអង្គរ ការរៀបចំពិធីព្រឹត្តិការណ៍ និងសកម្មភាពនានាពាក់ព័ន្ធនឹងការលើកតម្លៃបេតិកភណ្ឌវប្បធម៌
- ចូលរួមផ្សព្វផ្សាយពីវិស័យទេសចរណ៍ តាមរយៈការរៀបចំនិងចូលរួមពិព័រណ៍ ថ្នាក់ជាតិនិងអន្តរជាតិ និងធ្វើទីផ្សារផលិតផលទេសចរណ៍ក្នុងតំបន់ស្ថិតក្រោម ការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរាឱ្យបានទូលំទូលាយ ទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីលើកកម្ពស់គុណតម្លៃអង្គរនិងទាក់ទាញភ្ញៀវទេសចរ
- យកចិត្តទុកដាក់ស្វែងរកដៃគូជាតិ និងអន្តរជាតិដើម្បីសហការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព
- យកចិត្តទុកដាក់ ក្នុងការសហការបង្កើតការងារជូនប្រជាពលរដ្ឋក្នុងតំបន់ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ
- រៀបចំបទដ្ឋានសម្រាប់គ្រប់គ្រងបេតិកភណ្ឌវប្បធម៌ លើកកម្ពស់ការថែរក្សាបេតិកភណ្ឌអរូបី និងស្តង់ដារស្តីពីបេតិកភណ្ឌ វប្បធម៌ ព្រឹត្តិការណ៍ ឬសកម្មភាពនានាដែលអនុវត្តនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដើម្បីលើកកម្ពស់គុណតម្លៃអង្គរ និងបង្កើនចំណូលថវិកាជាតិ
- ចូលរួមរៀបចំគ្រប់គ្រងពិធីផ្សេងៗប្រព្រឹត្តនៅតាមប្រាសាទក្នុងតំបន់ឧទ្យានអង្គរ និងតំបន់ស្ថិតក្រោមការគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ដើម្បីពង្រឹងគុណភាពសេវាទេសចរណ៍ដោយសហការជាមួយស្ថាប័ន/អង្គភាព និងនាយកដ្ឋានពាក់ព័ន្ធ
- រៀបចំ និងគ្រប់គ្រងសារមន្ទីរ និងអភិរក្សវត្ថុបុរាណក្នុងសារមន្ទីរ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងទៅតាមការចាត់ចែងរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ឱ្យបានល្អស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៥
## នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា៩.-**

នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធមានមុខងារ និងភារកិច្ចដូចតទៅ ÷

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែងក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរាស្តីពី ការគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ចូលរួមអនុវត្តសកម្មភាព ដែលមានលក្ខណៈពហុវិស័យនៅក្នុងគម្រោងអភិវឌ្ឍន៍ ប្រកបដោយចីរភាព
- បង្កើតប្រព័ន្ធតាមដានបម្រែបម្រួលទឹកនៅលើដី និងក្រោមដី
- ធ្វើការវាស់វែងធារទឹកនៅតាមបណ្តាញផ្លូវទឹក
- ស្រាវជ្រាវ និងជួសជុលឡើងវិញនូវប្រព័ន្ធផ្លូវទឹកបុរាណ
- ស្រាវជ្រាវរកដំណោះស្រាយផ្សេងៗ ដើម្បីចាត់ចែងប្រើប្រាស់ទឹកនៅលើដីសម្រាប់ជួយកាត់បន្ថយការប្រើប្រាស់ទឹកនៅក្រោមដី
- បង្កើតប្រព័ន្ធតាមដានស្វ័យប្រវត្តិអំពីទឹកក្រោមដី តាមដានកម្ពស់ទឹកក្រោមដី និងធ្វើផែនទីខ្សែកម្ពស់ទឹកក្រោមដីតាមរដូវកាល
- តាមដានគុណភាពទឹកក្រោមដី និងធ្វើផែនទីអំពីការវិវត្ត
- តម្លើងប្រព័ន្ធស្ថានីយឧតុនិយមសម្រាប់ប្រមូលទិន្នន័យនៅក្នុងផ្ទៃអាងរងទឹកភ្លៀង
- តម្លើងប្រព័ន្ធតាមដានគុណភាពខ្យល់ចល័ត និងអចិន្ត្រៃយ៍
- បង្កើតប្រព័ន្ធទិន្នន័យក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងបច្ចេកវិទ្យាផ្កាយរណប ដើម្បីសម្រួលដល់ការគ្រប់គ្រងស្ថានភាពក្នុងតំបន់ ជាពិសេសក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- ផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចពីហានិភ័យ ដែលកើតមានឡើងដោយការបំពុលបរិយាកាស
- លើកសំណើពីដំណោះស្រាយសម្រាប់ធានាការជួយទ្រទ្រង់សុខភាព និងសុខុមាលភាពសាធារណៈ និងសុវត្ថិភាពរបស់ប្រាង្គប្រាសាទ
- អប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់ទឹកស្អាត អនាម័យ និងការគ្រប់គ្រងកាកសំណល់រឹង និងរាវ
- សិក្សាស្វែងរករុក្ខជាតិ និងសត្វក្នុងទឹក ដើម្បីប្រើប្រាស់ក្នុងការកែលម្អគុណភាពទឹកក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- យកចិត្តទុកដាក់ស្តារគម្របព្រៃឈើ និងផលិតជីកំប៉ុស្តិ៍តាមបែបធម្មជាតិ ដើម្បីធានាផ្គត់ផ្គង់ដល់ការដាំដុះ
- រៀបចំ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌព្រៃឈើ និងដីព្រៃ ព្រមទាំងកំណត់ហានិភ័យ ដើមឈើ
- រៀបចំបណ្តុះកូនឈើ សម្រាប់ការដាំដុះក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា
- ការពារជីវចម្រុះ ការងារអភិរក្សសត្វ និងរុក្ខជាតិក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

- សិក្សា និងរៀបចំទីលានមុខប្រាសាទ "ប៉ារីស" ចំណតមជ្ឈមណ្ឌលបដិសណ្ឋារកិច្ច មណ្ឌលផ្ដល់ព័ត៌មាន និងទីលានជុំវិញប្រាសាទ ស្របតាមបទដ្ឋាននៃការអភិវឌ្ឍន៍ និងអភិរក្សក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំឯកសារបច្ចេកទេសសម្រាប់គម្រោងជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ផ្លូវ ថ្នល់ ស្ពាន ។ល។
- ផ្ដល់សេវាពាក់ព័ន្ធនឹងការងារថានលេខា ឧបករណ៍បច្ចេកទេស និងឯកសារ បច្ចេកទេសសំខាន់ៗតាមការស្នើសុំរបស់នាយកដ្ឋាន ឬអង្គភាពនានា ។
- រៀបចំប្រមូលព័ត៌មាន ទិន្នន័យ និងឯកសារជិនួយស្មារតីពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- តាមដាន និងជួសជុលនូវហេដ្ឋារចនាសម្ព័ន្ធនានា ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា
- រៀបចំគម្រោងសំណង់គ្រប់ប្រភេទ
- គ្រប់គ្រងការងារអគ្គិសនីរបស់អាជ្ញាធរជាតិអប្សរា
- ធ្វើរបាយការណ៍សរុប ស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្ដីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៦
## នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍

**មាត្រា១០.-**

នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ មានមុខងារនិងភារកិច្ចដូចតទៅ ÷

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ដីពីការគ្រប់គ្រងដីធ្លី លំនៅដ្ឋាន សំណង់ បេតិកភណ្ឌក្រុងនានា និងកិច្ចការវត្តអារាម ស្របតាមកិច្ចការពារទេសភាពវប្បធម៌នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- កំណត់រាល់តំបន់ដែលត្រូវធ្វើការរៀបចំ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ស្របតាមបទដ្ឋាននៃការអភិរក្ស និងអភិវឌ្ឍន៍នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- សិក្សា អង្កេត និងវាស់វែងដីធ្លីគ្រប់ប្រភេទនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយស្ថាប័ន/អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ចូលរួមដោះស្រាយផលប៉ះពាល់ក្នុងគម្រោងអភិរក្ស និងអភិវឌ្ឍន៍ផ្សេងៗរបស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយស្ថាប័ន/អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- សិក្សា រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យដីធ្លីលំនៅដ្ឋាន សំណង់ និងប្រជាសាស្ត្រ ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយក្រសួង-ស្ថាប័ន/អង្គភាពពាក់ព័ន្ធ

- សិក្សា និងរៀបចំបទប្បញ្ញត្តិ និងវិធានពាក់ព័ន្ធក្នុងការគ្រប់គ្រងដីធ្លី និងការចេញលិខិត/ប័ណ្ណសម្គាល់សិទ្ធិដីធ្លី ដែលស្ថិតនៅក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរ ជូនប្រជាពលរដ្ឋដែលតាំងទីលំនៅ និងរស់នៅយូរលង់មកហើយ និងតាមដានការអនុវត្តបទប្បញ្ញត្តិនិងវិធានទាំងនោះ ដោយសហការជាមួយក្រសួង-ស្ថាប័ន/អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ពិនិត្យបែបបទចេញលិខិត/ប័ណ្ណសម្គាល់សិទ្ធិ ដីធ្លី ក្នុងឧទ្យានអង្គរស្របតាមបទប្បញ្ញត្តិជាធរមាន ដោយសហការជាមួយក្រសួង-ស្ថាប័ន/អង្គភាព និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ពិនិត្យ ដោះស្រាយ និងរៀបចំចុះបញ្ជីដីធ្លី និងបុរាណដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ពិនិត្យសំណើសុំជួសជុល សាងសង់ បញ្ជាក់ក្បាលដី និងរៀបចំលិខិតអនុញ្ញាតសាងសង់ ស្របទៅតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានពិនិត្យការសាងសង់ និងចេញលិខិត បញ្ជាក់ថាការសាងសង់នោះត្រឹមត្រូវតាមការណែនាំនិងនីតិវិធីរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំឱ្យមានក្រុមអង្កេតប្រជាសាស្ត្រ ព្រមទាំងដាក់ឱ្យដំណើរការជាប្រចាំ និងតាមដានការវិវត្តកំណើន និងការប្រែប្រួលទីលំនៅរបស់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ
- រៀបចំគំរូប្លង់ស្ថាបត្យកម្មខ្មែរបុរាណគ្រប់ប្រភេទ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ
- រៀបចំការអនុវត្តគម្រោងសហការជាមួយអន្តរជាតិក្នុងការអភិវឌ្ឍន៍និងលើកតម្កើងជីវភាពប្រជាជនក្នុងឧទ្យានអង្គរ និងតំបន់ផ្សេងៗទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ជំរុញឱ្យមានការអប់រំសហគមន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឧទ្យានអង្គរ
- បង្កើតឱ្យមានក្រុមទំនាក់ទំនងផ្សារភ្ជាប់ផ្នែកបច្ចេកទេស និងអាជ្ញាធរដែនដី អំពីកិច្ចការអភិវឌ្ឍន៍និងអភិរក្សនៅក្នុងឧទ្យានអង្គរ និងតំបន់ផ្សេងៗទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ពិនិត្យនិងផ្តល់យោបល់លើសំណើរបស់ក្រុមការងារសហគមន៍
- ពិនិត្យ និងផ្តល់យោបល់ ព្រមទាំងសិក្សាលើលទ្ធភាពនៃការជួសជុលពាក់ព័ន្ធនឹង កិច្ចការពារបេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប ជាពិសេសវត្តអារាមពុទ្ធសាសនា ដែលមានលក្ខណៈប្រវត្តិសាស្ត្រ លំនៅដ្ឋាន ប្រពៃណី និងអគារស្ថាបត្យកម្មដែលមានតម្លៃបេតិកភណ្ឌ តាមការស្នើសុំពី អាជ្ញាធរមានសមត្ថកិច្ច
- ចូលរួមសហការ សិក្សារៀបចំប្លង់លម្អិតក្នុងតំបន់ ដែលមានលក្ខណៈជាក្រុងនៃតំបន់សៀមរាបតាមការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ច
- សិក្សា និងរៀបចំឯកសារស្តីពីវិធានការពាក់ព័ន្ធនឹងការងារនគរូបនីយកម្ម សម្រាប់រក្សាតុល្យភាព រវាងការអភិវឌ្ឍន៍របស់ក្រុង/តំបន់រណបនៃតំបន់សៀមរាប និងការងារអភិរក្សបេតិកភណ្ឌវប្បធម៌ និងបរិស្ថាន
- ចូលរួមរៀបចំការកំណត់ទិសដៅបទដ្ឋាន និងនីតិវិធីក្នុងការប្រើប្រាស់ដី ព្រមទាំងបទដ្ឋានក្នុងការសាងសង់នៅទីរួមខេត្តសៀមរាប និងតំបន់រណបដោយសហការជាមួយអាជ្ញាធរដែនដី និងមន្ទីរពាក់ព័ន្ធនានា

- អភិរក្ស និងលើកតម្លៃទេសភាពវប្បធម៌ ដោយភ្ជាប់ជាមួយនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា តាមទស្សនទានដែលកំណត់ដោយអាជ្ញាធរជាតិអប្សរា
- យកចិត្តទុកដាក់លើកតម្លៃ និងការពារទេសភាពធម្មជាតិ ដែលពាក់ព័ន្ធជាមួយប្រពៃណីប្រវត្តិសាស្ត្រខ្មែរ
- សហការអនុវត្តសកម្មភាពដែលមានលក្ខណៈពហុវិស័យ នៅក្នុងគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ធ្វើរបាយការណ៍សរុបស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្ដីពីសភាពការណ៍ ចាំបាច់បន្ទាន់ពាក់ព័ន្ធការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៧

## នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

**មាត្រា១១.-**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ ÷

- រៀបចំផែនការស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ របស់អាជ្ញាធរជាតិអប្សរា សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ ដៃគូជាតិនិងអន្តរជាតិ
- សិក្សាស្រាវជ្រាវ និងអភិរក្សវត្ថុបុរាណធ្វើអំពីដីដុត លោហៈធាតុ ឈើ ភ្លុក ឆ្អឹង ថ្ម កែវ និងសារធាតុ សរីរាង្គដទៃទៀត ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- រៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ការស្រាវជ្រាវបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សង្គម និងប្រជាសាស្ត្រដែលទាក់ទងនឹងបេតិកភណ្ឌរូបី និងអរូបីរបស់អង្គរ ព្រមទាំងវិស័យផ្សេងៗទៀត ពាក់ព័ន្ធនឹងការងារក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា លើការងារអភិរក្សបេតិកភណ្ឌ និងអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ដោយសហការជាមួយនាយកដ្ឋាន/អង្គភាពរបស់អាជ្ញាធរជាតិអប្សរា ស្ថាប័នជាតិ និងអន្តរជាតិ
- តាមដាន និងពិនិត្យរាល់គម្រោង និងការដ្ឋានស្រាវជ្រាវ ដែលរៀបចំឡើង ដោយដៃគូជាតិនិងអន្តរជាតិ
- តាមដាន និង គ្រប់គ្រងនូវការបោះពុម្ពលើរាល់លទ្ធផលស្រាវជ្រាវដោយដៃគូសហការជាតិអន្តរជាតិរបស់អាជ្ញាធរជាតិអប្សរា និងចាត់វិធានការសមស្របចំពោះការផ្សព្វផ្សាយជាសាធារណៈ ដែលពុំមានការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា ឬប៉ះពាល់ដល់តម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានអង្គរ
- គ្រប់គ្រងបណ្ណាល័យ ឯកសារ បណ្ណសារ និងមន្ទីរពិសោធន៍នានារបស់អាជ្ញាធរជាតិអប្សរា

- បង្កើតប្រព័ន្ធទិន្នន័យ ដើម្បីចុះបញ្ជីលទ្ធផលស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា និងរបស់ស្ថាប័នជាតិ និងអន្តរជាតិ
- ផ្តល់យោបល់លើសំណើសុំនាំសំណាកទៅវិភាគនៅក្រៅប្រទេស ដោយដៃគូជាតិនិងអន្តរជាតិដែលស្រាវជ្រាវក្នុងឧទ្យានអង្គរ និងក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា
- រៀបចំ និងគ្រប់គ្រងប័ណ្ណចេញ ចូលឧទ្យានអង្គរ ដោយឥតគិតថ្លៃសម្រាប់អ្នកស្រាវជ្រាវអន្តរជាតិ
- សិក្សាចងក្រង និងផ្សព្វផ្សាយគ្រប់ឯកសារគតិយុត្ត និងវិធានការនានាទាក់ទង នឹងកម្មសិទ្ធិបញ្ញា អនុសញ្ញាពាក់ព័ន្ធនឹងបេតិកភណ្ឌពិភពលោករូបី និងអរូបី ព្រមទាំងក្រឹត្យក្រមបទដ្ឋានរបស់អង្គការយូណេស្កូ
- ចងក្រង ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តក្រមប្រតិបត្តិអង្គរ សម្រាប់អ្នកស្រាវជ្រាវ
- រៀបចំអនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងឯកសារស្តីពីកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរាជាមួយដៃគូជាតិ និងអន្តរជាតិ លើវិស័យស្រាវជ្រាវ អភិរក្ស អភិវឌ្ឍន៍នានា ដែលពាក់ព័ន្ធនឹងអាជ្ញាធរជាតិអប្សរា ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- រៀបចំបោះពុម្ពផ្សាយទស្សនាវដ្តី វិទ្យាសាស្ត្រ របស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- ទទួលបន្ទុកផ្សព្វផ្សាយការងាររបស់អាជ្ញាធរជាតិអប្សរាជូនស្ថាប័នជាតិ អន្តរជាតិ អ្នកសារព័ត៌មាន និងសាធារណជន តាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗទៀត
- រៀបចំព័ត៌មាន ផលិតវីដេអូឯកសារ បទយកការណ៍ វេទិកាសាធារណៈស្តីពីសកម្មភាពអភិរក្ស និងអភិវឌ្ឍន៍ លទ្ធផលស្រាវជ្រាវ និងគម្រោងនានារបស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយនាយកដ្ឋាន/អង្គភាពព្រមទាំងក្រុមការងារពាក់ព័ន្ធ
- តាមដានព័ត៌មាន ឆ្លើយតប និងបំភ្លឺទៅវិញឱ្យបានទាន់ពេលវេលា ដោយសហការជាមួយក្រុមការងារព័ត៌មានរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងៗទៀតរបស់អាជ្ញាធរជាតិអប្សរា
- លើកគម្រោងរៀបចំយុទ្ធនាការឃោសនា ផ្សព្វផ្សាយ ជូនសិស្សានុសិស្ស ប្រជាពលរដ្ឋនៅតាមសហគមន៍ក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ស្តីពីការការពារបេតិកភណ្ឌ និងតួនាទីរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំ និងបោះពុម្ពផ្សាយឯកសារ ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី និងគេហទំព័ររបស់អាជ្ញាធរជាតិអប្សរា
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៨
## នាយកដ្ឋានសណ្តាប់ធ្នាប់

**មាត្រា១២.-**

នាយកដ្ឋានសណ្តាប់ធ្នាប់ មានមុខងារនិងភារកិច្ចដូចតទៅ÷

- ទប់ស្កាត់រាល់សំណង់ខុសច្បាប់និងគ្មានការអនុញ្ញាត ដកហូតមករក្សាទុកនូវសម្ភារនិងមធ្យោបាយប្រើប្រាស់ ព្រមទាំងចាត់វិធានការរដ្ឋបាលនានាពាក់ព័ន្ធនឹងសំណង់ខុសច្បាប់ និងគ្មានការអនុញ្ញាត នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ទប់ស្កាត់រាល់សកម្មភាពខុសច្បាប់ និងគ្មានការអនុញ្ញាត ដែលធ្វើឱ្យប៉ះពាល់ ដល់តម្លៃបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ អរិយធម៌ ទំនៀមទំលាប់ ប្រពៃណី ជំនឿ សាសនា ទេសភាពវប្បធម៌ ការស្រាវជ្រាវខុសច្បាប់ សណ្តាប់ធ្នាប់ ការជីកកកាយ ការចាក់លុបដី ការរៀបចំ ព្រឹត្តិការណ៍ និងពិធីផ្សេងៗ នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- អនុវត្តតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន ហើយក្នុងករណីពិសេសអាចស្នើសុំកិច្ចសហការជាមួយមេធាវី ក្រុមការងារអ្នកច្បាប់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- ដឹកនាំអនុវត្តកិច្ចអន្តរាគមន៍ និងវិធានការរុះរើចំពោះសំណង់ខុសច្បាប់ ឬគ្មានការអនុញ្ញាតនៅតាមគោលដៅនានា ក្នុងរមណីយដ្ឋានអង្គរ និងតំបន់នានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងជាមួយបណ្តានាយកដ្ឋាន/អង្គភាពនានារបស់អាជ្ញាធរជាតិអប្សរា
- ចាត់វិធានការនានាក្នុងការទប់ស្កាត់ ការជួញដូរវត្ថុបុរាណ ការបំផ្លាញព្រៃឈើ ការទន្ទ្រានយកដី ការលួចជីកកកាយ ការស្រាវជ្រាវគ្មានការអនុញ្ញាត ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា
- រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សន្តិសុខសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាសនព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី៩
## នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ

**មាត្រា១៣.-**

នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យមានមុខងារនិងភារកិច្ចដូចតទៅ ÷

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងស្នើសុំថវិកាសម្រាប់កិច្ចអន្តរាគមន៍បន្ទាន់ ដោយសហការជាមួយនាយកដ្ឋាន អង្គភាពនានា និងក្រុមការងារដែលពាក់ព័ន្ធ

- តាមដាន និងត្រួតពិនិត្យប្រាក់ចំណូលគ្រប់ប្រភេទរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំគម្រោងថវិកា ជាមួយបណ្ដានាយកដ្ឋាន និងអង្គភាពនានា និងក្រុមការងារទាំងឡាយនៃអាជ្ញាធរជាតិអប្សរា ដើម្បីសុំការសម្រេចពីអគ្គនាយកអាជ្ញាធរជាតិអប្សរាមុនការអនុវត្តចំណាយ
- តាមដាន និងពិនិត្យចំនួនប្រាក់ និងរតនភ័ណ្ឌដែលមានផ្ញើនៅធនាគារ
- អនុវត្តការបើកប្រាក់ឧបត្ថម្ភ និងប្រាក់បំណាច់ផ្សេងៗជូនមន្ត្រីរាជការ និងជូនបុគ្គលិក គ្រប់ប្រភេទតាមការកំណត់របស់អគ្គនាយកអាជ្ញាធរជាតិអប្សរា
- កាន់កាប់បញ្ជីគណនេយ្យទូទៅរបស់អាជ្ញាធរជាតិអប្សរា និងបញ្ជីគណនេយ្យនៃប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗឱ្យមានតម្លាភាព និងគណនេយ្យភាពដោយតម្កល់ទុកនូវឯកសារដើម បញ្ជាក់ពីចំណូល-ចំណាយ
- គ្រប់គ្រងទ្រព្យសម្ភារគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ទទួលបន្ទុកផ្គត់ផ្គង់ទ្រព្យសម្ភារគ្រប់ប្រភេទ ប្រេងឥន្ធនៈ និងគ្រឿងបរិក្ខារផ្សេងៗទៀត ទៅតាមការសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា
- រៀបចំកិច្ចសន្យាសម្រាប់គម្រោងវិនិយោគ និងអាជីវកម្មនានា ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- គ្រប់គ្រងការប្រមូលចំណូល និងទូទាត់ចំណាយរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់អាជ្ញាធរជាតិអប្សរា ស្របតាមគោលនយោបាយយុទ្ធសាស្ត្រដែលក្រសួងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានកំណត់ និងផែនការសកម្មភាពរបស់អាជ្ញាធរជាតិអប្សរា ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់អាជ្ញាធរជាតិអប្សរា
- ធ្វើទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិការបស់អាជ្ញាធរជាតិអប្សរា
- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមជាសេនាធិការ របស់អគ្គនាយកអាជ្ញាធរជាតិអប្សរាសម្រាប់ការតាមដានត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដារគណនេយ្យ របាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មរបស់អាជ្ញាធរជាតិអប្សរាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ជូនប្រធានក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ អនុម័ត រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់ បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី១០
## នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

**មាត្រា១៤.-**

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក មានមុខងារនិងភារកិច្ចដូចតទៅ ÷

- សម្របសម្រួលការងារទទួលលិខិតចេញ-ចូល ការងារគ្រប់គ្រងចរាចរណ៍លិខិតផ្ទៃក្នុង ការតម្កល់ឯកសារ និងការងារឆ្លងឆ្លើយ ក៏ដូចជាទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ
- រៀបចំ និងសម្របសម្រួលការផ្ញើលិខិតឆ្លើយតប និងលិខិតអនុញ្ញាតផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិ ឱ្យស្របទៅតាមបទដ្ឋានរដ្ឋបាល និងពិនិត្យអំពីអនុលោមភាពនៃបទដ្ឋានរដ្ឋបាលទៅលើលិខិត និងអត្ថបទទាំងឡាយរបស់អាជ្ញាធរជាតិអប្សរា មុននឹងផ្ញើចេញទៅស្ថាប័នខាងក្រៅ
- សិក្សា និងរៀបចំលក្ខខណ្ឌរដ្ឋបាល និងស្ថាប័ន ដើម្បីធានាការគ្រប់គ្រងត្រា ដែលស្ថិតក្រោមការចាត់ចែងផ្ទាល់របស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ប្រកបដោយតម្លាភាព ប្រសិទ្ធភាពនិងស្របតាមបទដ្ឋានជាធរមានសម្រាប់អំណាចសាធារណៈ
- គ្រប់គ្រងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា និងសម្របសម្រួលការផ្តល់សេវាកម្មនានារបស់អាជ្ញាធរជាតិអប្សរា
- គ្រប់គ្រង និងចាត់ចែងការងារព័ត៌មានវិទ្យា និងនិវានុវត្តន៍ ពិធីការ សណ្តាប់ធ្នាប់ និងសន្តិសុខនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា
- ផ្តល់កិច្ចសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ស្ថាប័នជាតិ និងអន្តរជាតិ ក្នុងការសម្របសម្រួលទំនាក់ទំនង និងរៀបចំសិក្ខាសាលា ពិធីសម្ពោធ ព្រឹត្តិការណ៍ និងពិធីបុណ្យផ្លូវការរបស់អាជ្ញាធរជាតិអប្សរា ក៏ដូចជាសហការរៀបចំពិធី ព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនៅក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា
- រៀបចំផែនការមេរបស់អាជ្ញាធរជាតិអប្សរាក្នុងការអភិរក្ស និងអភិវឌ្ឍន៍តំបន់សៀមរាប-អង្គរ ដោយសហការជាមួយនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃអាជ្ញាធរជាតិអប្សរា
- គ្រប់គ្រងសំណុំបែបបទ និងនីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិកគ្រប់ប្រភេទ និងមន្ត្រីរាជការរបស់អាជ្ញាធរជាតិអប្សរា
- រៀបចំកំណត់តំណែងឯកទេស មុខតំណែងការងារ តួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិក
- រៀបចំការជ្រើសរើសបុគ្គលិកទៅតាមផែនការ និងនីតិវិធី រៀបចំតារាងប្រាក់ឧបត្ថម្ភសម្រាប់ការងារនីមួយៗរបស់មន្ត្រីរាជការ និងបុគ្គលិក រៀបចំការងារពិធីការ និងមគ្គុទ្ទេសក៍ទេសចរតាមការចាំបាច់នានា សម្រាប់បម្រើដល់គណៈប្រតិភូជាតិ និងអន្តរជាតិសំខាន់ៗដែលអញ្ជើញមកទស្សនានៅតំបន់សៀមរាប-អង្គរ
- គ្រប់គ្រងយានដ្ឋាន យានយន្ត គ្រឿងចក្រ ព្រមទាំងសម្ភារបរិក្ខារផ្សេងៗ
- រៀបចំរបាយការណ៍សកម្មភាព និងផែនការការងារ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់អាជ្ញាធរជាតិអប្សរា

- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមី និងសកម្មភាព ការងាររបស់អាជ្ញាធរជាតិអប្សរា ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធ នឹងការងាររបស់ខ្លួនជូនអគ្គនាយកអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ។

## ជំពូកទី១១
## អង្គភាពសវនកម្មផ្ទៃក្នុង

**មាត្រា១៥.-**

អង្គភាពសវនកម្មផ្ទៃក្នុង ត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

អង្គភាពសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា១៦.-**

មន្ត្រីរាជការក្នុងមុខតំណែងបច្ចុប្បន្ន ត្រូវបានរក្សាទុកនូវភារកិច្ច មុខងារ និងតួនាទី របស់ខ្លួនរហូតដល់មានការតែងតាំង ឬប្រគល់ភារកិច្ចថ្មី ។

## ជំពូកទី១៣
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៧.-**

ចំពោះបុព្វសិទ្ធិ និងសមត្ថកិច្ចរបស់អាជ្ញាធរជាតិអប្សរាដែលពាក់ព័ន្ធ ឬដែលអាចពាក់ព័ន្ធជាមួយបុព្វសិទ្ធិនិងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នផ្សេងៗទៀត រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ត្រូវសហការកំណត់ដោយប្រកាសរួម ។

## ជំពូកទី១៤
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា អនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ អនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៩រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែ...កក្កដា...ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិអប្សរា



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៦០៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានៈ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** ដំឡើងឋានៈលោកស្រី **ជា ទិត្យាយ៉ា** ជំនួយការឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយករង**។

**មាត្រា២ :** តែងតាំងលោកស្រី **យឹម ស្រីពៅ** ជាជំនួយការឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥២ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើត និងតែងតាំងក្រុមលទ្ធកម្ម
# របស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត និងតែងតាំងក្រុមលទ្ធកម្មនៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចតទៅ÷

| | | |
|---|---|---|
| ១. ឯកឧត្តម | **អ៊ឹម សិទ្ធីរ៉ា** | ជាប្រធាន |
| ២. លោក | **ស្រ៊ាង លឹមស្រួយ** | ជាអនុប្រធាន |
| ៣. លោក | **ពិន និលឡា** | ជាសមាជិក |
| ៤. លោក | **ស្រេង ចំរើន** | ជាសមាជិក |
| ៥. លោក | **ចន្សា ច័ន្ទសុគ័ន្ធ** | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើត និងតែងតាំងក្រុមលទ្ធកម្ម របស់អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាស នៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ..០១៩៩..ន.ថ.ស/ប្រក..លអ.....ចុះថ្ងៃទី.....១១............ខែ.កុម្ភៈ.........ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០១៩៩..ន.ថ.ស/ប្រក.លអ ចុះថ្ងៃទី....១១....ខែ....កុម្ភៈ.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តត្បូងឃ្មុំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែ..មាឃ......ឆ្នាំជូត..ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១១...ខែ.កុម្ភៈ....ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តត្បូងឃ្មុំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០១ រថ.អប្រក.ប្រក.

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២០១ រថ.អប្រក.ឈអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ របស់លោកស្រី កែវ សុផល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១**.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោ **ស្ថានីយប្រេងឥន្ធនៈ សុខ សំណាង** ស្ថិតនៅភូមិរុន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ របស់លោកស្រី **កែវ សុផល** (ម្ចាស់ស្ថានីយ)។

**ប្រការ២**.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣**.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤**.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានបន្ទប់ស្នាក់នៅក្នុងបរិវេណស្ថានីយ

២. ត្រូវសង់របងជញ្ជាំងកម្ពស់៣ម៉ែត្រធ្វើពីវត្ថុធាតុមិនឆេះ បាំងជិតនៅព្រំដីស្ថានីយប៉ែកខាងលំនៅដ្ឋាន

៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពីរបងព្រំដីស្ថានីយ និងចម្ងាយអប្បបរមា៦ម៉ែត្រ ពីលំនៅដ្ឋាន

៤. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ម៉ែត្រពីអគារក្នុងស្ថានីយ(លំនៅដ្ឋាន)

៥. ពោងប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រពីលំនៅដ្ឋាន

៦. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៨. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០២០១ ែរ.ក.ឈ ..........ចុះថ្ងៃទី......០១............ខែ កុម្ភៈ.........ឆ្នាំ២០២១.....................របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៧០០.១៥.អ២ក.ល៤ ចុះថ្ងៃទី....១១.....ខែ...កុម្ភៈ.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តតាកែវ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើតខែ.មាឃ.......ឆ្នាំជូត ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១១...ខែ..កុម្ភៈ....ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តតាកែវ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០៣ រថ.អប្រក.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២០៣ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយចម្រុះ



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់លោកស្រី ខា សុខលាង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

# សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ ដេប៉ូតេលា ពិសិដ្ឋ សុខលាង ស្ថិតនៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង របស់លោកស្រី ខា សុខលាង (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តកំពង់ឆ្នាំង
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ក្បាលដីស្ថានីយគួរមានប្រវែងអប្បបរមា ២៥ ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋាននៅក្នុងបរិវេណស្ថានីយ
៣. ចម្ងាយពីបំពង់ខ្យល់ទៅលំនៅដ្ឋានត្រូវមានប្រវែងអប្បបរមា ៦ ម៉ែត្រ

ក្រសួងរ៉ែ និង ថាមពល

៤. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៥. ពោងប្រេងឥន្ធនៈត្រូវកប់ក្នុងអាងធ្វើពីបេតុងអាមេ មិនជ្រាបទឹក ឬ ប្រេង
៦. ចុងបំពង់ខ្យល់ទៅប្រភពបញ្ចេះ (ផ្ទះបាយ) ត្រូវមានប្រវែងអប្បបរមា ៧ ម៉ែត្រ
៧. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៨. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៩. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១០. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១១. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១២. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១៣. ត្រូវរៀបចំឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.–**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.–**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២០៣.ឧស.អធក.ឋអ.......... ចុះថ្ងៃទី.....១១..... ខែ...កុម្ភៈ...... ឆ្នាំ២០២១............... របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០២០៣.ឧស.អធក.ឋអ. ចុះថ្ងៃទី....១១.......ខែ...កុម្ភៈ.......... ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ឆ្នាំង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍..១៤កើត ខែ..មាឃ......ឆ្នាំជូត..ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ..កុម្ភៈ.....ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ឆ្នាំង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២១៣ រថ.អប្រក.ប្រក.

# ប្រកាស

## ស្ដីពី

## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០២១៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ សូគីម៉ិច ស្ថិតនៅផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ របស់ ក្រុមហ៊ុន សុខ គង់ អាហារ៍ណ នីហារ៍ណ (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធររាជធានីភ្នំពេញ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ចម្ងាយពីពោងកប់ទៅព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ២,៥ ម៉ែត្រ

២. ទីតាំងបំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីព្រំដីស្ថានីយ

៣. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងនីមួយៗ

៤. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៥. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០៧១៦ រ៉ែ.ថព.បែក.ធារ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០៧១ រ៉ែ.អសហក.លអ ចុះថ្ងៃទី.....១៥.....ខែ...កុម្ភៈ........ឆ្នាំ២០.២១..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ.....៤កើត..ខែ..ផល្គុន.....ឆ្នាំ.ជូត..ទោស័ក.ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៥...ខែ..កុម្ភៈ....ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១០៥ ដនសណ/ប្រ.ក/នី.ក

# ប្រកាស

## ស្តីពី

## បែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ គម្រោងប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យ



អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

លេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ ក្នុងគោលបំណងដើម្បីអនុវត្តអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ៖

១- ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់អនុវត្តដោយក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់អនុវត្តដោយអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់** សំដៅដល់ការត្រួតពិនិត្យ ការវិភាគ ការផ្ទៀងផ្ទាត់ និងការបញ្ជាក់អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ការងាររុះរើ ឬការប្តូរមុខងារប្រើប្រាស់សំណង់

ដើម្បីជាមូលដ្ឋានសម្រាប់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

២- **ការប្ដូរមុខងារប្រើប្រាស់សំណង់** សំដៅដល់ការប្តូរមុខងារប្រើប្រាស់សំណង់ទាំងមូលឬដោយផ្នែក ឬការប្ដូរមុខងារសមាសភាគសំណង់ក្នុងគោលដៅអាជីវកម្ម ដោយមិនមានការជួសជុល កែប្រែ ឬរុះរើ។

៣- **គម្រោងប្លង់** សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀតសម្រាប់ការងារសាងសង់ឬរុះរើនិងការប្រើប្រាស់សំណង់។

៤- **ត្រាវិជ្ជាជីវៈ** សំដៅដល់ត្រាចេញដោយគណៈវិជ្ជាជីវៈពាក់ព័ន្ធជូនដល់អ្នកវិជ្ជាជីវៈសម្រាប់ប្រើប្រាស់ក្នុងការប្រកបវិជ្ជាជីវៈ។

៥- **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដើម្បីបញ្ជាក់អំពីអនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

៦- **ស្តង់ដាកម្ពុជា** សំដៅដល់ស្តង់ដាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិនិងប្រកាសឱ្យប្រើដោយរដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម សម្រាប់អនុវត្តចំពោះសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

៧- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៨- **អ្នកសិក្សាគម្រោងប្លង់** សំដៅដល់អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនឬអង្គភាពរដ្ឋ ដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់។

៩- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

១០- **ឯកសារទម្រង់អេឡិចត្រូនិក** សំដៅដល់ឯកសារដែលផ្ទុកនូវព័ត៌មាន ឬទិន្នន័យដែលអាចយកមកដំណើរការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងចែករំលែករវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

១១- **ឯកសារទម្រង់ឌីជីថល** សំដៅដល់ ទី១)ឯកសារដែលមានទម្រង់ជា Portable Document Format(PDF) ឬរូបភាព(JPEG,PNG,...) សម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ដែលបានស្កែនឬថតចេញពីឯកសាររូបី ឬ ទី២)ឯកសារដែលមានទម្រង់ជា PDF ឬរូបភាពដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

១២- **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក សេចក្ដីណែនាំបច្ចេកទេស ប្លង់សម្រង់សំណង់ ប្លង់សម្រង់តាមការសាងសង់ជាក់ស្ដែង សលាកបត្រក្បាលដី វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ របាយការណ៍ស្ដីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ លិខិតបញ្ជាក់អនុលោមភាព របាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ របាយការណ៍ស្ដីពីការពិសោធន៍ របាយការណ៍ស្ដីពីការគណនា របាយការណ៍ស្ដីពីការធ្វើកោសល្យវិច័យសំណង់ គោលការណ៍ចេញដោយស្ថាប័នឬអាជ្ញាធរពាក់ព័ន្ធ និងគម្រោងប្លង់ឬរបាយការណ៍បច្ចេកទេសដទៃទៀត។

១៣- **ឯកសាររឹង** សំដៅដល់ឯកសារដែលមានទម្រង់ជាក្រដាស។

## ជំពូកទី២

## វិធានរួមនៃការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់

**ប្រការ៤._**

ចំណាត់ថ្នាក់ ប្រភេទ និងទំហំនៃសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ត្រូវបានកំណត់ដូចតទៅ៖

១- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

២- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

**ប្រការ៥._**

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ អាចធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះសំណង់ដូចតទៅ៖

១- សំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជនដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

២- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីសំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជនដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពុំមានការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃគម្រោងប្លង់សំណង់នោះ។

ក្នុងករណីសំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពុំមានការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ដោយអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃគម្រោងប្លង់សំណង់នោះ។

**ប្រការ៦**._

ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់សម្រាប់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ការងាររុះរើ និងការប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវអនុវត្តតាមបែបបទដូចមានចែងក្នុងប្រកាសនេះ។

ម្ចាស់សំណង់ត្រូវចុះកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាមួយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណនៅមានសុពលភាព ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់របស់ខ្លួន មុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

រាល់ការចំណាយសម្រាប់ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ជាបន្ទុករបស់ម្ចាស់សំណង់។

**ប្រការ៧**._

ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ ត្រូវអនុវត្តទៅលើគម្រោងប្លង់ដែលអ្នកសិក្សាគម្រោងប្លង់បានសិក្សារួចនិងមិនទាន់បានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច។

ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ ត្រូវអនុវត្តផ្អែកលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិជាធរមានដទៃទៀត និងឯកសារបច្ចេកទេសសម្រាប់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ការងាររុះរើ ឬការប្តូរមុខងារប្រើប្រាស់សំណង់។

ក្នុងករណីចាំបាច់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទៅដល់ទីតាំងជាក់ស្តែងនៃគម្រោងសាងសង់ ឬការដ្ឋានសំណង់ ឬសំណង់ ដើម្បីធ្វើការវាយតម្លៃនិងសន្និដ្ឋាន។

**ប្រការ៨._**

ម្ចាស់សំណង់ត្រូវប្រគល់ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ នូវឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការងារដែលជាកម្មវត្ថុនៃគម្រោងប្លង់។

ក្នុងករណីបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតតម្រូវ ម្ចាស់សំណង់ត្រូវប្រគល់ឯកសារបច្ចេកទេសផ្សេងទៀតពាក់ព័ន្ធនឹងការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ការងាររុះរើ និងការប្តូរមុខងារប្រើប្រាស់សំណង់ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចស្នើសុំម្ចាស់សំណង់ឱ្យប្រគល់ឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ការងាររុះរើ និងការប្តូរមុខងារប្រើប្រាស់សំណង់ ដើម្បីបង្កើនសុក្រឹតភាពនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់និងកាត់បន្ថយការចំណាយរបស់ម្ចាស់សំណង់។

ក្រោយពីទទួលបានឯកសារបច្ចេកទេសពីម្ចាស់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវចេញលិខិតប្រគល់ទទួលឯកសារដែលមានកាលបរិច្ឆេទនិងហត្ថលេខារបស់ភាគីទាំងពីរ។

គំរូទម្រង់លិខិតប្រគល់ទទួលឯកសារបច្ចេកទេស ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៩._**

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ម្ចាស់សំណង់ត្រូវប្រគល់ប្លង់ស្ថាបត្យកម្មនិងសេចក្តីណែនាំបច្ចេកទេសជាឯកសាររឹងនិងជាឯកសារទម្រង់ឌីជីថល ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវប្រគល់ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនាជាឯកសាររឹង ឯកសារទម្រង់ឌីជីថល និងឯកសារទម្រង់អេឡិចត្រូនិក ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្នុងករណីម្ចាស់សំណង់ប្រគល់ប្លង់និងសេចក្តីណែនាំបច្ចេកទេសជាឯកសាររឹងជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឯកសារទាំងនោះត្រូវមានហត្ថលេខា គោត្តនាមនិងនាម ត្រាវិជ្ជាជីវៈ និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈសិក្សាគម្រោងប្លង់ ឬហត្ថលេខានិងគោត្តនាមនិងនាមរបស់អ្នកបច្ចេកទេសនិងនាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់។

ក្នុងករណីម្ចាស់សំណង់ប្រគល់ប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនា ជាឯកសារទម្រង់ឌីជីថល និងឯកសារទម្រង់អេឡិចត្រូនិក ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ម្ចាស់សំណង់ត្រូវអនុវត្តដូចតទៅៈ

១- ត្រូវការពារប្រឆាំងនឹងការផ្លាស់ប្តូរទិន្នន័យនៃប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនានោះ។

២- ត្រូវប្រគល់ប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនាជាឯកសារទម្រង់ឌីជីថល និងឯកសារទម្រង់អេឡិចត្រូនិក ដំណាលគ្នាជាមួយនឹងការប្រគល់គម្រោងប្លង់ជាឯកសាររឹង។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់មានសិទ្ធិចម្លងទិន្នន័យនៅក្នុងឯកសារទម្រង់ឌីជីថលនិងឯកសារទម្រង់អេឡិចត្រូនិកដើម្បីប្រើប្រាស់សម្រាប់តែការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ប៉ុណ្ណោះ។

**ប្រការ១០._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងចេញលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ជូនម្ចាស់សំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់បានតែម្តងគត់ លើកលែងតែមានការតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់និងលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ ត្រូវធ្វើយ៉ាងតិចជា៥(ប្រាំ)ច្បាប់ និងត្រូវប្រគល់ជូនម្ចាស់សំណង់ចំនួន៣(បី)ច្បាប់ ប្រគល់ជូនអ្នកសិក្សាគម្រោងប្លង់ចំនួន១(មួយ)ច្បាប់ និងរក្សាទុកដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ចំនួន១(មួយ)ច្បាប់។

របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ ត្រូវមានហត្ថលេខា គោត្តនាមនិងនាម ត្រាវិជ្ជាជីវៈ និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខានិងគោត្តនាមនិងនាមរបស់អ្នកបច្ចេកទេសនិងនាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ ត្រូវមានហត្ថលេខា គោត្តនាមនិងនាម ត្រាវិជ្ជាជីវៈ និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខានិងគោត្តនាមនិងនាម របស់នាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬ ហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

នៅលើគ្រប់សន្លឹកប្លង់ត្រូវមានហត្ថលេខា គោត្តនាមនិងនាម និងត្រាវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈ ត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខានិងគោត្តនាមនិងនាមរបស់នាយកបច្ចេកទេស និងត្រារបស់ ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងកាលបរិច្ឆេទនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

លិខិតបញ្ជាក់អនុលោមភាពមួយ ត្រូវចេញសម្រាប់គម្រោងប្លង់មួយ និងត្រូវបង្ហាញបទប្បញ្ញត្តិ បច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតដែលជាមូលដ្ឋាននៃអនុលោមភាព។

គំរូទម្រង់លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ១១**._

ក្នុងករណីអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ពិនិត្យឃើញថាគម្រោងប្លង់មានចំណុចខ្វះចន្លោះឬ មិនត្រឹមត្រូវផ្នែកទម្រង់និង/ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវចេញលិខិតជូនដំណឹងទៅម្ចាស់សំណង់ ដើម្បីសម្រប សម្រួលឱ្យអ្នកសិក្សាគម្រោងប្លង់បំពេញបន្ថែមឬកែតម្រូវ។ លិខិតជូនដំណឹងត្រូវបង្ហាញរាល់ចំណុច ខ្វះចន្លោះឬមិនត្រឹមត្រូវផ្នែកទម្រង់និង/ឬរាល់ចំណុចដែលមិនអនុលោមទាំងអស់នៃគម្រោងប្លង់ ព្រមទាំង កំណត់រយៈពេលសម្រាប់ធ្វើការបំពេញបន្ថែមនិង/ឬកែតម្រូវ។

រយៈពេលសម្រាប់ធ្វើការបំពេញបន្ថែមនិង/ឬកែតម្រូវចំណុចខ្វះចន្លោះឬមិនត្រឹមត្រូវផ្នែកទម្រង់ និង/ឬមិនអនុលោមនៃគម្រោងប្លង់ មិនរាប់បញ្ចូលក្នុងរយៈពេលអនុវត្តកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យ និងបញ្ជាក់សំណង់ឡើយ។

ក្នុងករណីចាំបាច់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់អាចអញ្ជើញអ្នកសិក្សាគម្រោងប្លង់មក ណែនាំដោយផ្ទាល់អំពីចំណុចខ្វះចន្លោះឬមិនត្រឹមត្រូវផ្នែកទម្រង់និង/ឬរាល់ចំណុចដែលមិនអនុលោម ទាំងអស់នៃគម្រោងប្លង់។

ផុតរយៈពេលសម្រាប់ធ្វើការបំពេញបន្ថែមនិង/ឬកែតម្រូវដូចមានចែងក្នុងកថាខណ្ឌខាងលើនិង ក្រោយពិនិត្យឃើញថាចំណុចខ្វះចន្លោះឬមិនត្រឹមត្រូវផ្នែកទម្រង់និង/ឬរាល់ចំណុចដែលមិនអនុលោម ទាំងអស់នៃគម្រោងប្លង់មិនត្រូវបានបំពេញឬកែតម្រូវ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញ

របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ជូនទៅម្ចាស់សំណង់ ដោយត្រូវបង្ហាញរាល់ចំណុចខ្វះចន្លោះឬមិនត្រឹមត្រូវផ្ទៃកទម្រង់និង/ឬមិនអនុលោមទាំងនោះ។

ផុតរយៈពេលសម្រាប់ធ្វើការបំពេញបន្ថែមនិង/ឬកែតម្រូវដូចមានចែងក្នុងកថាខណ្ឌខាងលើនិងក្រោយពិនិត្យឃើញថាចំណុចខ្វះចន្លោះឬមិនត្រឹមត្រូវផ្ទៃកទម្រង់និង/ឬរាល់ចំណុចដែលមិនអនុលោមទាំងអស់នៃគម្រោងប្លង់ ត្រូវបានបំពេញឬកែតម្រូវ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់និងចេញលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ជូនទៅម្ចាស់សំណង់។

គំរូទម្រង់លិខិតជូនដំណឹង ជាឧបសម្ព័ន្ធ៣នៃប្រកាសនេះ។

## ជំពូកទី៣
## ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម

**ប្រការ១២._**

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការងារសាងសង់សំណង់ថ្មីឬការងារកែប្រែ ត្រូវអនុវត្តមុនការស្នើសុំលិខិតអនុញ្ញាតសាងសង់។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការងារជួសជុល ត្រូវអនុវត្តមុនការស្នើសុំលិខិតអនុញ្ញាតជួសជុល។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការងាររុះរើ ត្រូវអនុវត្តមុនការស្នើសុំលិខិតអនុញ្ញាតរុះរើ។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវអនុវត្តមុនការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

**ប្រការ១៣._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ត្រូវអនុវត្តតួនាទីនិងភារកិច្ច មានជាអាទិ៍៖

១- ត្រួតពិនិត្យនិងប្រើប្រាស់បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម បទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដាកម្ពុជា និងគោលការណ៍ណែនាំបច្ចេកទេសជាធរមានដែលពាក់ព័ន្ធក្នុងការសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម។

២- ត្រួតពិនិត្យថាគម្រោងប្លង់ស្ថាបត្យកម្ម ត្រូវបានសិក្សាស្របតាមប្រភេទ ទំហំ និងមុខងារប្រើប្រាស់របស់សំណង់។

៣- ផ្ទៀងផ្ទាត់ថាសំណង់ដែលសាងសង់ឬរុះរើស្របតាមគម្រោងប្លង់ស្ថាបត្យកម្ម មានសុវត្ថិភាពអគ្គិភ័យ និងបន្ទប់សុវត្ថិភាពអគ្គិភ័យ។

៤- ផ្ទៀងផ្ទាត់ថាសំណង់ដែលសាងសង់ឬរុះរើស្របតាមគម្រោងប្លង់ស្ថាបត្យកម្ម អាចប្រើប្រាស់បានប្រកបដោយផាសុកភាព បរិស្ថានល្អ និងសន្សំសំចៃថាមពល។

ចំពោះគម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការងារជួសជុល អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ថា សំណង់ដែលជួសជុលស្របតាមគម្រោងប្លង់នោះ រក្សាបាននូវសោភណភាព និងទ្រង់ទ្រាយដើមនៃសំណង់។

ចំពោះគម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ការងាររុះរើដោយផ្នែក អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ថា សមាសភាគនៃសំណង់ដែលនៅសល់មានលក្ខណៈត្រឹមត្រូវទៅតាមប្រភេទ ទំហំ និងមុខងារប្រើប្រាស់។

**ប្រការ១៤._**

ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ត្រូវអនុវត្តលើទិដ្ឋភាពដូចតទៅ៖

១- ផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ផ្លូវ ឬ ផ្លូវ កម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណៈ ផ្ទៃបៃតង ចំណតយានយន្តក្រៅអគារ។

២- ផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួច ជណ្តើរ កម្ពស់ ច្រកចេញចូល លំហ ខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរួបរួមបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព មុខងារប្រើប្រាស់សំណង់ មុខងារសមាសភាគសំណង់។

៣- ផ្នែកប្រព័ន្ធទឹកកខ្វក់និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្តាញលូបង្ហូរទឹកកខ្វក់ បណ្តាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

៤- ផ្នែកសុវត្ថិភាព មានជាអាទិ៍ ផែនទីជម្លៀស ច្រកសុវត្ថិភាព ជណ្តើរសង្គ្រោះ បន្ទប់សុវត្ថិភាពអគ្គិភ័យ ឧបករណ៍ការពាររន្ទះ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ។

៥- ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ជាឧបសម្ព័ន្ធ៨នៃប្រកាសនេះ។

## ជំពូកទី៤

## ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់

**ប្រការ១៥.**_

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់សម្រាប់ការងារសាងសង់សំណង់ថ្មី ការងារកែប្រែ និងការងាររុះរើ ត្រូវអនុវត្តមុនការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់សម្រាប់ការងារជួសជុល ត្រូវអនុវត្តមុនការស្នើសុំលិខិតអនុញ្ញាតជួសជុល។

ការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់សម្រាប់ការប្ដូរមុខងារប្រើប្រាស់សំណង់ ត្រូវអនុវត្តមុនការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

**ប្រការ១៦.**_

អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តតួនាទីនិងភារកិច្ច មានជាអាទិ៍៖

១- ត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ថាគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវបានសិក្សាស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលត្រូវបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច។

២- ត្រួតពិនិត្យនិងប្រើប្រាស់បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធក្នុងការសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់។

៣- ត្រួតពិនិត្យនិងប្រើប្រាស់បទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដាកម្ពុជា បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់សម្ភារៈសំណង់និងផលិតផលសំណង់ក្នុងការសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់។

៤- យល់ដឹងពីការសន្មត ដែនកំណត់ និងក្បួនគណនានៃកម្មវិធីកុំព្យូទ័រដែលបានប្រើប្រាស់សម្រាប់ការបង្កើតគំរូ ការវិភាគ និងការគណនាគ្រឿងផ្គុំសំណង់។

៥- បង្កើតគំរូគ្រឿងផ្គុំ វិភាគ និងគណនាដោយឯករាជ្យដើម្បីកំណត់ភាពគ្រប់គ្រាន់ និងភាពធន់រឹងមាំនៃរាល់សមាសភាគគ្រឿងផ្គុំសំណង់ ដោយគិតទាំងគ្រឿងផ្គុំផ្នែកខាងក្រោមនិងគ្រឿងផ្គុំផ្នែកខាងលើ។

៦- ផ្ទៀងផ្ទាត់ការកំណត់ ការគណនា និងការជ្រើសរើសបន្ទុកគណនា។

៧- ផ្ទៀងផ្ទាត់វិធីសាស្ត្រនិងលទ្ធផលនៃការវិភាគគ្រឿងផ្គុំសំណង់។

៨- ផ្ទៀងផ្ទាត់លក្ខខណ្ឌនិងការគណនាសមាសភាគនៃគ្រឿងផ្គុំសំណង់។

៩- ផ្ទៀងផ្ទាត់ថា ភាពដាប ភាពរេ ភាពស្រុត ភាពវិល ភាពញ័រ និងស្នាមប្រេះ នៃគ្រឿងផ្គុំសំណង់ ស្ថិតក្នុងដែនកំណត់នៃបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធ។

១០- ផ្ទៀងផ្ទាត់ថាប្លង់លម្អិតគ្រឿងផ្គុំសំណង់ បានបញ្ចូលនូវទិដ្ឋភាពទាំងអស់នៃការគណនាគ្រឿងផ្គុំ។

១១- ត្រួតពិនិត្យថាប្លង់គ្រឹះនៃសំណង់ ត្រូវបានសិក្សាអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេស គោលការណ៍ណែនាំបច្ចេកទេស និងការពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកទេសភូគព្ភសាស្ត្រ មានជាអាទិ៍ ការសិក្សាអង្កេតដី ការពិសោធន៍គុណភាពសសរគ្រឹះ ការពិសោធន៍លទ្ធភាពទ្រទ្រង់របស់សសរគ្រឹះ។

១២- ផ្ទៀងផ្ទាត់ថាស្ថិរភាពនៃគ្រឿងផ្គុំសំណង់ សមស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ស្តង់ដាកម្ពុជា បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ។

១៣- ចំពោះគ្រឿងផ្គុំខ្ពស់ ត្រូវពិនិត្យដល់ភាពចាំបាច់នៃការវិភាគឌីណាមិកសម្រាប់បន្ទុកដែលគិតបញ្ចូលក្នុងការគណនា មានជាអាទិ៍ បន្ទុកខ្យល់ បន្ទុករញ្ជួយដី ក្នុងករណីបើមាន។

១៤- ត្រួតពិនិត្យការសិក្សាគម្រោងប្លង់និងសេចក្តីណែនាំបច្ចេកទេសក្នុងការដំឡើងប្រព័ន្ធជញ្ជាំងទប់ដីសម្រាប់សាងសង់គ្រឿងផ្គុំផ្នែកខាងក្រោម។

១៥- ត្រួតពិនិត្យសមាសភាគនៃគ្រឿងផ្គុំសំណង់បណ្តោះអាសន្ននិងអចិន្ត្រៃយ៍ទាំងឡាយដែលបានសាងសង់ឡើង ដើម្បីធានាមិនឱ្យប៉ះពាល់ដល់សំណង់ជិតខាង។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ ជាឧបសម្ព័ន្ធ ៥នៃប្រកាសនេះ។

**ប្រការ១៧.**_

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវប្រគល់របាយការណ៍ស្តីពីការគណនាគ្រឿងផ្គុំសំណង់ជាឯកសារទម្រង់ឌីជីថលឬឯកសាររឹងជូនម្ចាស់សំណង់សម្រាប់បំពេញបែបបទស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ លិខិតអនុញ្ញាតជួសជុល ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

## ជំពូកទី៥
## កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់

**ប្រការ១៨.-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវចុះកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាមួយម្ចាស់សំណង់ទៅតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណ។

កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចតទៅ៖

- កាលបរិច្ឆេទបង្កើតកិច្ចសន្យា
- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យា កាលបរិច្ឆេទ និងរបៀបនៃការទូទាត់
- ការអះអាងអំពីការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ការអះអាងអំពីអនុលោមភាពនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការផ្តល់ឯកសារបច្ចេកទេសសម្រាប់ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់តាមទំហំនិងប្រភេទនៃការងារ
- ការធានាការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌនៃការកែប្រែនិងការរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងវិជ្ជាជីវៈនិងការទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កឡើងដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់
- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

គំរូទម្រង់កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាឧបសម្ព័ន្ធ៦នៃប្រកាសនេះ។

**ប្រការ១៩._**

កម្រៃសេវានិងកាលបរិច្ឆេទនៃការទូទាត់សម្រាប់កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើតាមការព្រមព្រៀងរវាងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់និងម្ចាស់សំណង់។

ក្នុងករណីគ្មានការព្រមព្រៀងរវាងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់និងម្ចាស់សំណង់ កម្រៃសេវានិងកាលបរិច្ឆេទនៃការទូទាត់សម្រាប់កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវអនុវត្តដូចខាងក្រោម៖

- ទូទាត់យ៉ាងតិច៧០(ចិតសិប)ភាគរយនៃតម្លៃកិច្ចសន្យានៅពេលចុះកិច្ចសន្យា
- ទូទាត់បង្គ្រប់នៅពេលប្រគល់ទទួលរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់និង/ឬលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់។

## ជំពូកទី៦

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**ប្រការ២០._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៅក្នុងការអនុវត្តការងាររបស់ខ្លួន។

**ប្រការ២១._**

ក្នុងករណីពុំមានបទប្បញ្ញត្តិបច្ចេកទេសសំណង់សម្រាប់ការងារសំណង់ណាមួយ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអនុវត្តតាមការជ្រើសរើសរបស់អ្នកសិក្សាគម្រោងប្លង់ ឬមន្ទីរពិសោធន៍សំណង់នូវបទដ្ឋានបច្ចេកទេសសំណង់ណាមួយដែលមានការទទួលស្គាល់កម្រិតអន្តរជាតិឬកម្រិតតំបន់និងត្រូវត្រួតពិនិត្យនិងបញ្ជាក់លើផ្នែកដែលពាក់ព័ន្ធនឹងសុវត្ថិភាពសំណង់តែប៉ុណ្ណោះ។ ក្នុងករណីនេះ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអះអាងអំពីចំណេះដឹងរបស់ខ្លួនក្នុងការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់នោះនៅក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់។

ការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ អាកាសធាតុ បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៧

## ការប្តឹងតវ៉ា

**ប្រការ២២._**

ម្ចាស់សំណង់ឬអ្នកសិក្សាគម្រោងប្លង់ដែលរងការខូចខាតឬមានការបារម្ភជាក់ស្តែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ២៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៣រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "**ដើម្បីជូនជ្រាប**"
- សាលារាជធានី ខេត្ត
- ដូចប្រការ២៤ "**ដើម្បីអនុវត្ត**"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ .....១០៩ ដនសា/ប្រក........ ចុះថ្ងៃទី ..២២..... ខែវិច្ឆិកា ឆ្នាំ២០២១
ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឈ្មោះនិង/ឬរូបសញ្ញា<br>អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ |
|---|

ថ្ងៃ ..................... ខែ .......... ឆ្នាំ ....... ......ស័ក ព.ស.២៥..

........................... ថ្ងៃទី .......... ខែ ............... ឆ្នាំ២០ .......

**លិខិតប្រគល់-ទទួលឯកសារបច្ចេកទេស**
**សម្រាប់ការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់**

យោងពាក្យស្នើសុំ/កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ ......................
..................................................................................................................
ចុះថ្ងៃទី ........... ខែ ........... ឆ្នាំ .............

□ គម្រោងប្លង់ស្ថាបត្យកម្ម
□ គម្រោងប្លង់គ្រឿងផ្គុំសំណង់
□ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក
□ សេចក្តីណែនាំបច្ចេកទេស
□ ប្លង់សម្រង់សំណង់
□ ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង
□ សលាកបត្រក្បាលដី
□ វិញ្ញាបនបត្រប្រើប្រាស់សំណង់
□ ឯកសារសិក្សាភូគព្ភសាស្ត្រ
